# សេចក្តីប្រកាសព័ត៌មានរួមស្តីពី ប្រទេសកម្ពុជាប្រកាសបើក យុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការ ជំងឺកញ្ជ្រឹល ស្អូចនៅទូទាំងប្រទេសដើម្បីការពារកុមារជាង១.៥ លាននាក់

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃ ព្រហស្បតិ៍ ទី ៣១ ខែ តុលា ឆ្នាំ២០២៤៖

ថ្ងៃនេះ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសអំពីការបើកយុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូច នៅទូទាំងប្រទេស ដល់កុមារចំនួនជាង១,៥លាននាក់ ដែលអាយុចាប់ពី ៩ខែ ដល់ ៥៩ខែ នៅ២៥ រាជធានី ខេត្ត។ យុទ្ធនាការនេះដឹកនាំផ្ទាល់ដោយក្រសួងសុខាភិបាល និងបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុដោយអង្គការសម្ព័ន្ធសកលសម្រាប់វ៉ាក់សាំង និងការផ្តល់ថ្នាំបង្ការ (Gavi) និងមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការសុខភាពពិភពលោក(WHO) អង្គការមូលនិធិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ (UNICEF) និងអង្គការគ្លីនតុនហែល្ស អែកសេស អ៊ីនីតស៊ីអេធីវ (CHAI)។

ដើម្បីឆ្លើយតបទៅនឹងការផ្ទុះរាតត្បាតជំងឺកញ្ជ្រឹលនៅលើទូទាំងពិភពលោក ជាពិសេសចំពោះប្រជាជនដែលមានភាពស៊ាំការពារទៅនឹងជំងឺកញ្ជ្រឹលទាប ដូច្នេះយុទ្ធនាការនេះជាដោះស្រាយជាបន្ទាន់មួយដើម្បីការពារពីការចម្លងជំងឺកញ្ជ្រឹលនេះ ។ នៅលើសកលលោក ចំនួនករណីជំងឺកញ្ជ្រឹកមានការកើនឡើងទ្វេរដងពី ១៧0,000 ករណី ក្នុងឆ្នាំ ២០២២ ដល់ ៣២0,000 ករណី ក្នុងឆ្នាំ២០២៣។ ដែលនេះមូលហេតុចម្បងដោយសារតែការរំខានដល់ការផ្តល់ថ្នាំបង្ការជាប្រចាំក្នុងអំឡុងពេលរីករាលដាលវីរុសកូវីដ១៩។

ប្រទេសកម្ពុជា និងប្រទេសជិតខាងកំពុងប្រឈមនឹងភាពងាយរងគ្រោះនៃការឆ្លងរីករាលដាលករណីជំងឺកញ្ជ្រឹល ស្អូចនេះ ជាពិសេសចំពោះប្រជាជនដែលងាយរងគ្រោះ ដូចជាកុមារ ជនអន្តោប្រវេសន៍ ប្រជាជនចល័ត និងសហគមន៍នៅតាមតំបន់ព្រំដែន។ យុទ្ធនាការយុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចទូទាំងប្រទេសនេះ គឺជាវិធានការសំខាន់មួយ ដើម្បីពង្រឹងសុវត្ថិភាពសុខាភិបាល ការពារពីការរីករាលដាលជំងឺនានា និងគាំទ្រដល់កម្ពុជាដើម្បីក្លាយជាប្រទេសដែលមិនមានករណីជំងឺកញ្ជ្រឹល។

**ឯកឧត្តម សាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល លើកទឹកចិត្តដល់បុគ្គលិកសុខាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ប្រឹងប្រែងធ្វើការសហការរួមគ្នាដើម្បីធានាបានថា អត្រាគ្រប់ដណ្តប់វ៉ាក់សាំងខ្ពស់ និងដើម្បីការពារកុមារទាំងអស់ទូរទាំងប្រទេសជៀសផុតពីជំងឺទាំងពីរនេះ។ **ឯកឧត្តម សាស្ត្រាចារ្យ** បានបន្ថែមទៀតថា *"អំឡុងពេលការយុទ្ធនាការផ្តល់ថ្នាំបង្ការមុនៗ បុគ្គលិកសុខាភិបាលបានបំពេញការងារបានល្អ ហើយខ្ញុំជឿជាក់ថាក្នុងយុទ្ធនាការលើកនេះផងដែរ បុគ្គលិកសុខាភិបាលនឹងបន្តការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពធ្វើយ៉ាងណាអាចផ្តល់ថ្នាំបង្ការដល់កុមារទាំងអស់ ជាពិសេសកុមារដែលរស់នៅតំបន់ដែលមានហានិភ័យខ្ពស់ និងកន្លែងដែលពិបាកដល់ដូចជាកុមាររស់នៅក្នុងគ្រួសារក្រីក្រនៅតាមទីក្រុង អ្នករស់នៅក្នុងសហគមន៍ដាច់*

*ស្រយាលនៅតាមជនបទ កុមារតូចជនជាតិភាគតិច និងកុមារអន្តោប្រវេសន៍* "។ ដោយយោងតាមការប៉ាន់ប្រមាណអត្រាគ្របដណ្ដប់ថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចនៅ ថ្នាក់ជាតិរបស់អង្គការសុខភាពពិភពលោក និងអង្គការមូលនិធិសម្រាប់កុមារនៃអង្គការសហប្រជាជាតិ (WUENIC) បានបង្ហាញថា នៅប្រទេសកម្ពុជាអត្រាគ្របដណ្ដប់វ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូចដូសទីមួយ(MR1) មាន៧៩% និងអត្រាគ្របដណ្ដប់វ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូចដូសទីពីរមានតែ៦៤%ប៉ុណ្ណោះនៅឆ្នាំ២០២៣ ។ ដែលទិន្នន័យនេះបង្ហាញថា អត្រាគ្របដណ្ដាបវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូច គឺស្ថិតនៅកម្រិតក្រោមតម្រូវការសម្រាប់ការបង្ការការផ្ទុះរាលដាលជំងឺ ជំងឺកញ្ជ្រឹល ស្អូច និង ការជៀសវាងការស្លាប់ដោយសារជំងឺកញ្ជ្រឹល ស្អូចនៅឡើយ ។

**លោកស្រីវេជ្ជបណ្ឌិត Marianna Trias** តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា បានមានប្រសាសន៍ថា *" ជំងឺកញ្ជ្រឹល ស្អូច គឺពិតជាមានហានិភ័យធ្ងន់ធ្ងរ ប៉ុន្តែជាជំងឺមួយដែលអាចការពារបានដោយវ៉ាក់សាំង ដែលកុមារកម្ពុជាមិនគួរមានបញ្ហានេះទេ "*។ យុទ្ធនាការផ្ដល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចនេះ គឺពិតជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកសមធម៌សុខាភិបាល ធានាថាមិនមាននរណាម្នាក់ត្រូវបានទុកចោលពីបេសកកម្មរបស់ពួកយើង។ ដើម្បីលើកកំពស់ការ ការពារ និងផ្ដល់សេវាសុខាភិបាលដល់ប្រជាជនទាំងអស់គ្នា និងគ្រប់ទីកន្លែង។ រួមគ្នាជាមួយក្រសួងសុខាភិបាល និង ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ក្នុងនាមអង្គការសុខភាពពិភពលោក (WHO) សូមប្ដេជ្ញា គាំទ្ររាល់សកម្មភាពទាំងឡាយដែលកម្មវិធីជាតិផ្ដល់ថ្នាំនង្ការដែលបានអនុវត្ត និង កំពង់អនុវត្តដើម្បីបំពេញបន្ថែប្រព័ន្ធភាពភាពស៊ាំរបស់សហគមន៍ និងដើម្បីពង្រឹងសុវត្ថិភាពសុខាភិបាល ព្រមទាំងការពារប្រជាជនគ្រប់រូបនៅក្នុងសហគមន៍ពីការផ្ទុះរាលដាលជំងឺកញ្ជ្រឹល ស្អូចនេះ និងធ្វើយ៉ាងណាឱ្យគ្រប់គ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជាមិនមានកើតមាននូវជំងឺកញ្ជ្រឹល ស្អូច។

**លោកស្រី Nadia Lasri** អ្នកគ្រប់គ្រងជាន់ខ្ពស់ប្រចាំប្រទេស និងជាអ្នកសម្របសម្រួលនៃការគាំទ្ររបស់អង្គការសម្ព័ន្ធសកលសម្រាប់វ៉ាក់សាំង និងការផ្ដល់ថ្នាំបង្ការ (Gavi) ប្រចាំកម្ពុជា បានមានប្រសាសន៍ថា " *ការគាំទ្ររបស់អង្គការ Gavi សម្រាប់យុទ្ធនាការផ្ដល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចនៅទូទាំងប្រទេសនេះ គឺដើម្បីបង្កើន និងបន្តការខិតខំប្រឹងប្រែងក្នុងការពង្រឹងការផ្ដល់ថ្នាំបង្ការជាប្រចាំរបស់កម្ពុជា។ ជំងឺកញ្ជ្រឹល ស្អូច នៅតែជាជំងឺដែលមានការគំរាមកំហែងចំពោះសុខភាពកុមារនៅទូទាំងសកលលោក ដូច្នេះហើយ យើងត្រូវតែបង្កើនការខិតខំទ្វេដងដើម្បីផ្ដល់ថ្នាំបង្ការដល់កុមារគ្រប់រូប ជាពិសេសដល់កុមារដែលមិនបានទទួលថ្នាំបង្ការនៅតំបន់ពិបាកទៅដល់ (Hard-to-reach areas) និងតំបន់ទីក្រុង ហើយត្រូវធានាថាគ្មានសហគមន៍ណាមួយត្រូវនៅសេសសល់ឡើយ។ ទាំងនេះ គឺជាជំហានមួយដ៏សំខាន់ដើម្បីឆ្ពោះទៅរកអនាគតកុមារដែលមានសុខភាពល្អនៅក្នុងប្រទេសកម្ពុជា*"។

**លោកវេជ្ជបណ្ឌិត Will Parks** ជាតំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជាបានមានប្រសាសន៍ថា *"ការផ្ដល់ថ្នាំបង្ការ គឺជាការងារនាំមុខមួយក្នុងការខិតខំប្រឹងប្រែងរបស់យើង ដើម្បីការពារកុមារដែលខ្វះខាតបំផុត។ តាមរយៈបទពិសោធន៍នេះ យើងបានដឹងថាការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយសហគមន៍*

*និងអាជ្ញាធរមូលដ្ឋានគឺជាគន្លឹះមួយដ៏សំខាន់ក្នុងការធ្វើឱ្យប្រាកដថាឪពុកម្ដាយ និងអ្នកថែទាំនាំកុមារបាននាំកុមារទៅទទួលថ្នាំបង្ការដែលនៅប៉ុស្តិ៍ផ្តល់ថ្នាំបង្ការដែលជិតបំផុត។ តាមរយៈការគាំទ្រយុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចនេះ យើងសង្ឃឹមថា យើងនឹងចូលរួមចំណែកបន្ថែមទៀតមួយទៀតដល់ការពង្រឹងប្រព័ន្ធសុខាភិបាលនៅកម្ពុជា ដើម្បីលើកកម្ពស់និរន្តរភាពនៃសេវាផ្តល់សេវាថ្នាំបង្ការប្រកបដោយគុណភាពនិងប្រសិទ្ធភាពដល់កុមារទាំងអស់។*

**លោកស្រី Soleine Scotney** នាយកអង្គការគ្លីនតុនហែល្ស អែកសេស អ៊ីនីតស៊ីអេធីវ (CHAI)ប្រចាំនៅកម្ពុជាមានប្រសាសន៍ថា " *វ៉ាក់សាំងកញ្ជ្រឹល ស្អូច គឺជាវ៉ាក់សាំងមួយប្រភេទដែលមានប្រសិទ្ធភាព និង មានឥទ្ធិពលបំផុតនៅលើពិភពលោក។ យើងសូមកោតសរសើរយ៉ាងខ្លាំង ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការរៀបចំយុទ្ធនាការយុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចដ៏មានសារៈសំខាន់មួយនេះ បន្ថែមលើនេះ ការពង្រឹងបន្ថែមទៀតនូវការផ្តល់ថ្នាំបង្ការការពារជំងឺកញ្ជ្រឹល ស្អូចជាប្រចាំដល់កុមារដែលមានអាយុចាប់ពី ៩ ខែ ដល់ ១៨ ខែ ទាំងអស់ នឹងអនុញ្ញាតឱ្យកុមារកម្ពុជាគ្រប់រូបទទួលបានអំណោយដ៏មានអានុភាពនេះ*"។

យុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូចនេះ នឹងប្រើប្រាស់វ៉ាក់សាំង និងសឺរ៉ាំងដែលត្រូវបានទទួលស្គាល់គុណភាពដោយអង្គការសុខភាពពិភពលោក (WHO) និងត្រូវបានធ្វើលទ្ធកម្មតាមរយៈប្រព័ន្ធលទ្ធកម្មរបស់អង្គការយូនីសេហ្វ(UNICEF)។ វ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូចនេះ គឺមានសុវត្ថិភាព ប្រសិទ្ធភាព និងទទួលដោយឥតគិតថ្លៃ ដែលអាចការពារកុមារទូទាំងពិភពលោកអស់រយៈពេលជាង៥០ឆ្នាំមកហើយ ព្រមទាំងអាចរកបាននៅគ្រប់មណ្ឌលសុខភាពទាំងអស់របស់ក្រសួងសុខាភិបាល។ កុមារទាំងអស់ដែលមានអាយុចាប់ពី ៩ខែ ដល់ ៥៩ខែ រួមទាំងកុមារដែលធ្លាប់កើតជំងឺកញ្ជ្រឹល ឬកុមារដែលបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូចពីមុនក៏ដោយ ត្រូវបានលើកទឹកចិត្តឱ្យទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល ស្អូចចំនួនមួយដូសបន្ថែមទៀតដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍ ដែលជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងសន្តិសុខភាព ដើម្បីទប់ស្កាត់ការផ្ទុះរាលដាលជំងឺ និង ការឆ្ពោះអនាគតដែលគ្មានជំងឺកញ្ជ្រឹល។

យុទ្ធនាការផ្តល់បន្ថែមថ្នាំបង្ការជំងឺកញ្ជ្រឹល ស្អូច នេះនឹងចែកចេញជាពីរដំណាក់កាល ដោយផ្តល់វ៉ាក់សាំងមួយដូសដល់កុមារទាំងអស់ដែលមានអាយុចាប់ពី ៩ខែ ដល់ ៥៩ខែ រួមទាំងកុមារដែលធ្លាប់កើតជំងឺកញ្ជ្រឹល ឬកុមារដែលបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល មួយដូស ឬច្រើនដូសពីមុន ។ ដំណាក់កាលទីមួយនឹងគ្របដណ្តប់ខេត្តចំនួន១៣ (បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ស្ពឺ កំពង់ធំ កណ្តាល ក្រចេះ ឧត្តរមានជ័យ ភ្នំពេញ ពោធិ៍សាត់ សៀមរាប ប៉ៃលិន និងខេត្តត្បូងឃ្មុំ) ចាប់ថ្ងៃទី១ ដល់ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៤ និង ដំណាក់កាលទីពីរ នឹងគ្របដណ្តប់ខេត្តចំនួន១២ (ខេត្តកំពង់ឆ្នាំង កំពត កោះកុង មណ្ឌលគិរី ព្រះវិហារ ព្រៃវែង រតនគិរី ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងខេត្តកែប) ចាប់ពី ថ្ងៃទី ២៥ ខែ វិច្ឆិកា ដល់ថ្ងៃទី ៦ ខែធ្នូ ឆ្នាំ២០២៤។

# ព័ត៌មានបន្ថែម សូមទាក់ទង ៖

**National Immunization Program, Ministry of Health**
Mr. Ork Vichit
Telephone: +855 (0)12830548
Email: orkvichit@yahoo.com

**WHO**
Lisa Smyth
Technical Officer, Coordination and Communication for Health
Telephone: +855 12 919 180
Email: smythl@who.int

**UNICEF**
Hadrien Bonnaud
Chief of Communication
Telephone: +855 92 555 294
Email: hbonnaud@unicef.org

Ty Chan
Communication officer
+855 92 284 262
Email: tchan@unicef.org

**CHAI**
Corina Milic
Director of Global Communications
+1 416 371 6313
cmilic@clintonhealthaccess.org

**GAVI**
Meg Sharafudeen
+41 79 711 55 54
msharafudeen@gavi.org

Eunice Kilonzo-Muraya
+41 76 424 85 03
ekilonzo@gavi.org